ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៦២/១៩ - វ៉ាយ ធី ស៊ី ខបប៉ូរេសិន
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **លីវ សុវណ្ណា**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន វ៉ាយ ធី ស៊ី ខបប៉ូរេសិន**
អាសយដ្ឋាន ៖ ភូមិចំបក់ ឃុំវល្លិ៍សរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
ទូរស័ព្ទ ៖ ០៧៧ ៧៧ ៧៨ ២៩ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖

១- លោក Lee Eunkyeng អ្នកគ្រប់គ្រងរោងចក្រ
២- លោក គង់ កុក ប្រធានផ្នែកអនុលោមច្បាប់

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន វ៉ាយ ធី ស៊ី ខបប៉ូរេសិន**
អាសយដ្ឋាន ៖ ភូមិចំបក់ ឃុំវល្លិ៍សរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
ទូរស័ព្ទ ៖ ០៩៣ ៥៥ ៦៦ ៤១ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

១- លោក ហម ស៊ុនរិទ្ធិ មេធាវី
២- លោកស្រី យ៉ាង សុភ័ណ្ឌ ប្រធានសហព័ន្ធសហជីពកម្ពុជា
៣- លោក សេង រាជ ជំនួយការមេធាវី
៤- លោក ម៉ៃ សាមិត្ត ប្រធានសហជីពកម្ពុជាប្រចាំក្រុមហ៊ុន វ៉ាយ ធី ស៊ី ខបប៉ូរេសិន

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh ♦ Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org ♦ Website: www.arbitrationcouncil.org

| | |
|---|---|
| ៥- លោក ឆែម វណ្ណៈ | អនុប្រធានសហជីពកម្ពុជាប្រចាំក្រុមហ៊ុន វ៉ាយ ឌី ស៊ី ឧបប៉ូរេសិន |
| ៦- លោកស្រី ប៊ុត មួយ | លេខាសហជីពកម្ពុជាប្រចាំក្រុមហ៊ុន វ៉ាយ ឌី ស៊ី ឧបប៉ូរេសិន |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ស្នើសុំឱ្យក្រុមហ៊ុនសងលុយ ៥% (ប្រាំភាគរយ) ត្រឡប់មកកម្មករវិញ និងលុយ ៧ថ្ងៃ។

២- ស្នើសុំឱ្យក្រុមហ៊ុនគិតលុយឱ្យបានត្រឹមត្រូវតាមច្បាប់ ប្រាំចំណុច ជូនបងប្អូនកម្មករ ហើយកុំ ដកលុយ ៥% (ប្រាំភាគរយ)។

៣- ស្នើសុំឱ្យក្រុមហ៊ុនបញ្ចូលកម្មករធ្វើការលើសពី ២ឆ្នាំ ទៅជាកិច្ចសន្យាមិនកំណត់។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សា អាជ្ញាកណ្ដាលលេខ ១៩១/១៩ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ (អាណត្តិទី១៧)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន វ៉ាយ ឌី ស៊ី ឧបប៉ូរេសិន លេខ ៣៥២៦/១៩ កប/កស្ក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩។

## សវនាការ និង សន្ទេបនីតិវិធី

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** ៖ ថ្ងៃពុធ ១៥រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ បានទទួលពាក្យបណ្ដឹងពីកម្មករនិយោជិត នៃក្រុមហ៊ុន វ៉ាយ ឌី ស៊ី ឧបប៉ូរេសិន ស្តីពីលក្ខខណ្ឌការងារចំនួន ៣ចំណុច។ បន្ទាប់ពីទទួលពាក្យបណ្ដឹងនេះមក មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះទៅតាមនីតិវិធីច្បាប់ ដោយមិនទទួលបានលទ្ធផលមិនសះជានឹងគ្នាទេ។ ចំណុចមិន

សះជាចំនួន ៣ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន វ៉ាយជីស៊ី ខបប៉ូរេសិន លេខ ៣៥២៦/១៩ កប/កស្ក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ៣ ចំណុច នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក។ ភាគីទាំងពីរ មានវត្តមានតាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមស្វះរកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទដែលនៅសល់ទាំង ៣ ចំណុចនេះ បន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ១ ចំណុច គឺភាគីបានព្រមព្រៀងគ្នាត្រង់ចំណុចវិវាទទី៣។ នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិតសម្រេចដាក់បញ្ចូលចំណុចវិវាទទី១ និងទី២ បញ្ចូលគ្នា ហើយក្នុងនោះ ភាគីទាំងពីរក៏បានព្រមព្រៀងគ្នាមួយផ្នែកនៅក្នុងចំណុចវិវាទនេះ ពាក់ព័ន្ធនឹងការទូទាត់ប្រាក់បំណាច់អតីតភាពចំនួន ៧ថ្ងៃ (មានកិច្ចព្រមព្រៀងដាច់ដោយឡែក)។ ចំពោះការទាមទារពាក់ព័ន្ធនឹងប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំនួន ៥ភាគរយ គឺទុកឱ្យក្រុមអាជ្ញាកណ្តាលសម្រេច។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាចំណុចវិវាទមិនសះជា ដែលនៅសល់ចំនួន ១ ចំណុច តែប៉ុណ្ណោះ គឺចំណុចវិវាទទី១ និងទី២ ពាក់ព័ន្ធការទាមទារឱ្យនិយោជកសងប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំនួន ៥ ភាគរយ ជូនកម្មករនិយោជិតវិញ។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

ភាគីទាំងពីរបានឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាលពីថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៩ ទៅយ៉ាងយូរត្រឹម ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើកស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិរបស់លោក Lee Eunkyeng អ្នកគ្រប់គ្រងទូទៅនៃក្រុមហ៊ុន វ៉ាយ ជី ស៊ី ខបប៉ូរេសិន ប្រគល់សិទ្ធិជូន លោក គង់ កុក ជាប្រធានផ្នែកអនុលោមច្បាប់ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩។

២- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន វ៉ាយ ជី ស៊ី ខបប៉ូរេសិន លេខ MOC-៧៧៦៥៣៨២៦ ពណ.ចបព ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៦។

៣- លក្ខន្តិកៈក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន ចុះទិដ្ឋាការលេខ ១៤០៨/១៩ គ.វ.ត ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ នៅនាយកដ្ឋាននីតិវិធី និងច្បាប់វិនិយោគ គ.វ.ក។

៤- លិខិតចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន គោរពជូន លោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ ស្តីពីសំណើសុំចុះទិដ្ឋាការលើបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។

៥- បទបញ្ជាផ្ទៃក្នុងនៃក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន ចុះទិដ្ឋាការលេខ ៣០៣១/១៥ កប/កស្ព ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ ដោយប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ។

៦- លិខិតលេខ ១៤០៨/១៩ គ.វ.ក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ របស់គណៈកម្មាធិការវិនិយោគកម្ពុជា ជម្រាបជូន លោកនាយកក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន ស្តីពីករណីសំណើសុំប្តូរអ្នកតំណាងម្ចាស់ភាគហ៊ុន ប្តូរអភិបាល និងតម្កល់លក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន។

៧- កំណត់ហេតុប្រជុំចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

៨- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៃក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ។

៩- ពាក្យបណ្តឹង និងចាត់តាំងប្រតិភូចរចា របស់កម្មករ-កម្មការិនី ក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន គោរពជូនប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ ស្តីពីស្នើសុំ ជួយផ្សះផ្សាវិវាទការងារ ជាមួយក្រុមហ៊ុន ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩។

១០- សេចក្តីបង្គាប់អាជ្ញាកណ្តាលសំណុំរឿងលេខ ៣៣០/១៥-គីន តាយ ហ្វាមិន ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦។

១១- លិខិតបញ្ចប់កិច្ចសន្យាការងាររបស់ក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៩ ជម្រាបជូនកម្មករឈ្មោះ កែវ សុខជា ,ណែម កន និង វ៉េង លីម ស្តីពីការបញ្ចប់កិច្ចសន្យាការងារ។

១២- របាយការណ៍ប្រាក់ឈ្នួលសរុបសម្រាប់បុគ្គលិកកម្មករត្រូវបញ្ចប់កិច្ចសន្យាការងារ (ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៩) ពាក់ព័ន្ធនឹងកម្មករឈ្មោះ កែវ សុខជា ,ណែម កន និង វ៉េង លីម។

១៣- លិខិតបញ្ជាក់ពីការយល់ព្រមរបស់កម្មករឈ្មោះ កែវ សុខជា ,ណែម កន និង វ៉េង លីម។

១៤- ឯកសារជាភាសាបរទេស។

១៥- ឯកសារជារូបភាព។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតតំណាងដោយអាណត្តិ ថ្ងៃសៅរ៍ ហង់ ស៊ុនរិទ្ធ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីតំណាងដោយអាណត្តិ ឱ្យអាណត្តិទាយកឈ្មោះ ម៉ែ

THE ARBITRATION COUNCIL

សាមិត្ត ភេទប្រុស ឆែម វណ្ណៈ ភេទប្រុស និង ប៊ុត មួយ ភេទស្រី ជាតំណាងកម្មករនៃរោងចក្រ វ៉ាយ ធី ស៊ី ឧបប៉ូរេសិន ក្នុងសំណុំរឿងលេខ ០៦២/១៩ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

២- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ របស់អាណត្តិទាយកឈ្មោះ ម៉ៃ សាមិត្ត ភេទប្រុស ឆែម វណ្ណៈ ភេទប្រុស និង ប៊ុត មួយ ភេទស្រី ជាកម្មករនៃរោងចក្រ វ៉ាយ ធី ស៊ី ឧបប៉ូរេសិន ដែលមានអាសយដ្ឋានស្ថិតនៅឃុំវល្លិ៍សរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ សូមប្រគល់សិទ្ធិជូន លោកមេធាវី ហាម ស៊ុនរិទ្ធិ។

៣- វិញ្ញាបនបត្រចុះបញ្ជិកាសហជីពកម្ពុជានៃរោងចក្រកាត់ដេរ វ៉ាយធីស៊ី ខេមបូឌា លេខ ៣២៨២ ក.ប/វក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥។

៤- លិខិតលេខ ០៥៩/១៥ ក.ប ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ របស់រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពកម្ពុជានៃរោងចក្រកាត់ដេរ វ៉ាយធីស៊ី ខេមបូឌា ជាអង្គការវិជ្ជាជីវៈមួយរបស់កម្មករនិយោជិត បានចុះបញ្ជិកានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពេញលក្ខណៈច្បាប។

៥- បញ្ជីឈ្មោះកម្មករនិយោជិតដែលមានអតីតភាពការងារលើសពី ២ឆ្នាំ ឱ្យប្តូរទៅជាកិច្ចសន្យាមានថិរវេលាមិនកំណត់។

៦- ពាក្យបណ្តឹង និងចាត់តាំងប្រតិភូចរចា ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ របស់កម្មករកម្មការនីនៃក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន គោរពជូន លោកប្រធានមន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ ស្តីពីសំណើសុំជួយផ្សះផ្សាវិវាទការងាររវាងកម្មករនិយោជិត និងក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន។

៧- បញ្ជីឈ្មោះកម្មករទាមទារឱ្យរោងចក្រគិតប្រាក់បំណាច់ឱ្យបានត្រឹមត្រូវតាមច្បាប់។

៨- សារណាតំណាងដោយអណត្តិ របស់មេធាវី ហាម ស៊ុនរិទ្ធ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសារណាការពារឱ្យអាណត្តិទាយកឈ្មោះ ម៉ៃ សម្បត្តិ ឆែម វណ្ណៈ និង ប៊ុត មួយ ក្នុងសំណុំរឿងលេខ ០៦២/១៩ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន លេខ ៣៥២៦/១៩ កប/កស្ក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន លេខ ០០៣ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ របស់មន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ។

THE ARBITRATION COUNCIL

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៣៦២ កប/អក/វក/លកអ. ចុះថ្ងៃពុធ ៨ រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៣៦៣ កប/អក/វក/លកអ. ចុះថ្ងៃពុធ ៨រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន វ៉ាយធីស៊ី ខបប៉ូរេសិន គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងក្នុងការផលិតសម្លៀកបំពាក់ និងបានទទួលវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ ០០០១២១០២ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៦។ ក្រុមហ៊ុននេះ មានជួលកម្មករនិយោជិតសរុបចំនួន ២១៣៦ នាក់ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន វ៉ាយធីស៊ី ខបប៉ូរេសិន)*។
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិត ក្នុងការដោះស្រាយវិវាទការងាររួម លេខ ០០៣ ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៩ ដែលមានកម្មករនិយោជិត ចំនួន ៣នាក់ មានឈ្មោះ ១.ម៉ៅ សាមិត្ត , ២. ឆែម វណ្ណៈ និង ៣.ប៊ុត មួយ ជាអ្នកតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន វ៉ាយធីស៊ី ខបប៉ូរេសិន ក្នុងការដោះស្រាយវិវាទការងាររួម។
- នៅថ្ងៃសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺមានវត្តមានរបស់កម្មករនិយោជិតដែលជាអ្នកតំណាងភាគីកម្មករនិយោជិតចំនួន ៣នាក់ ខាងលើ។
- ករណីនេះ មិនមានអង្គហេតុណាមួយបញ្ជាក់ថា នៅក្នុងក្រុមហ៊ុននេះ មានសហជីពដែលមានភាពជាតំណាងបំផុតទេ។

**ចំណុចវិវាទទី១ និងទី២៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកសងប្រាក់ ៥ភាគរយ ត្រឡប់មកកម្មករនិយោជិតវិញ និងប្រាក់ ៧ថ្ងៃ និងទាមទារឱ្យក្រុមហ៊ុនគិតប្រាក់ឱ្យបានត្រឹមត្រូវតាមច្បាប់ប្រាំចំណុច ជូនកម្មករនិយោជិតហើយកុំដកប្រាក់ ៥ភាគរយ**

- នៅថ្ងៃសវនាការ ភាគីទាំងពីរបានព្រមព្រៀងគ្នាមួយផ្នែកក្នុងចំណុចវិវាទនេះ គឺពាក់ព័ន្ធនឹងប្រាក់បំណាច់អតីតភាពការងារ ចំនួន ៧ថ្ងៃ (ដោយមាននៅក្នុងកិច្ចព្រមព្រៀងមួយដាច់ដោយឡែក)។ ហេតុនេះ ការទាមទារដែលនៅសល់ គឺមានតែចំណុចវិវាទដែលពាក់ព័ន្ធនឹងការទាមទារឱ្យនិយោជកសងប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំនួន ៥ភាគរយ ជូនកម្មករនិយោជិតតែប៉ុណ្ណោះ។
- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារថា ឱ្យនិយោជកសងប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំនួន ៥ភាគរយ ជូនកម្មករនិយោជិតចំនួន ៧៣ នាក់វិញ ទោះបីជានិយោជកបានទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារចំនួន ៥ ចំណុច តាមច្បាប់ហើយក៏ដោយ។
- ភាគីទាំងពីរទទួលស្គាល់ថា៖

- កម្មករនិយោជិតចំនួន ៧៣ នាក់ ដែលទាមទារនៅក្នុងសំណុំរឿងនេះ ត្រូវបាននិយោជកបញ្ចប់កិច្ចសន្យាការងារ ដោយមូលហេតុក្រុមហ៊ុនត្រូវការកាត់បន្ថយបុគ្គលិក។
- នៅពេលបញ្ចប់កិច្ចសន្យាការងារ គឺនិយោជកបានទូទាត់ប្រាក់បំណាច់ផ្ដាច់កិច្ចសន្យាការងារចំនួន ៥ចំណុច មានប្រាក់បំណាច់បណ្ដេញចេញ, ប្រាក់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់, ប្រាក់បំណាច់ទូទាត់ជួសការជូនដំណឹងមុន, ប្រាក់សោហ៊ុយជំងឺចិត្ត និងប្រាក់ឈ្នួលចុងក្រោយ ជូនពួកគាត់តាមប្រភេទកិច្ចសន្យាការងារមានថិរវេលាមិនកំណត់។ ប៉ុន្តែ និយោជកបានដកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំនួន ៥ភាគរយ ដែលកម្មករនិយោជិតធ្លាប់ទទួលបានកន្លងមក នៅពេលចប់កិច្ចសន្យាការងារដែលមានកំណត់ថិរវេលាម្ដងៗនោះមកវិញ។

- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា៖
  - និយោជកមិនមានសិទ្ធិដកយកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំនួន ៥ភាគរយ ដែលធ្លាប់ឱ្យកម្មករនិយោជិតកន្លងមកនោះទេ ព្រោះការផ្ដល់ឱ្យនេះ គឺមានលក្ខណៈប្រសើរជាងច្បាប់ យោងតាមមាត្រា ១៣ នៃច្បាប់ស្ដីពីការងារ ដោយមូលហេតុថា បើតាមច្បាប់គឺនិយោជកមិនត្រូវឱ្យប្រាក់ ៥ភាគរយ នេះទេ រាល់ពេលចប់កិច្ចសន្យាការងារដែលមានថិរវេលាកំណត់ម្ដងៗ ព្រោះកម្មករនិយោជិតនៅតែបន្តធ្វើការ ប៉ុន្តែករណីនេះ និយោជកបានផ្ដល់ប្រាក់ ៥ភាគរយ ហេតុនេះ វាជាការអនុវត្តដែលប្រសើរជាងច្បាប់។
  - មិនមានច្បាប់កំណត់ថា និយោជកមានសិទ្ធិដកយកប្រាក់ ៥ភាគរយនេះ ទៅវិញនោះទេ ទោះបីជា និយោជកបានទូទាត់ប្រាក់បំណាច់ផ្ដាច់កិច្ចសន្យាការងារមានថិរវេលាមិនកំណត់ត្រឹមត្រូវតាមច្បាប់ក៏ដោយ។
  - ការដកយកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំនួន ៥ភាគរយនេះ និយោជកមិនបានប្រាប់កម្មករនិយោជិតមុននោះទេ ការដកយកនេះ គឺជាឆន្ទៈរបស់និយោជកតែម្ខាង ដោយគ្មានការព្រមព្រៀងពីកម្មករនិយោជិតនោះទេ។

- ភាគីនិយោជកលើកឡើងថា និយោជកមិនអាចអនុវត្តតាមការទាមទាររបស់កម្មករនិយោជិតខាងលើបានទេ ដោយមូលហេតុថា៖
  - ការបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំង ៧៣នាក់ ខាងលើនេះ គឺនិយោជកបានទូទាត់ប្រាក់បំណាច់ផ្ដាច់កិច្ចសន្យាការងារចំនួន ៥ចំណុច ត្រឹមត្រូវតាមប្រភេទកិច្ចសន្យាការងារមានថិរវេលាមិនកំណត់រួចហើយ។ ហេតុនេះ និយោជកនឹងដកយកប្រាក់ ៥ភាគរយ ដែលកម្មករនិយោជិតធ្លាប់ទទួលបាន ក្នុងពេលប្រើកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាមកវិញ។
  - មានសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ ៣៣០/១៥-ក្រុមហ៊ុន គីនតាយ បានសម្រេចបដិសេធការទាមទាររបស់កម្មករនិយោជិត មិនឱ្យនិយោជកដកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំនួន ៥ភាគរយ មកវិញ។ នេះមានន័យថា និយោជកមានសិទ្ធិក្នុងការដកយកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំនួន ៥ភាគរយ មកវិញ នៅពេលដែលនិយោជកបានទូទាត់ប្រាក់បំណាច់ត្រឹមត្រូវតាមប្រភេទកិច្ចសន្យាការងារមានថិរវេលាមិនកំណត់រួចហើយ។

- នៅក្នុងសេចក្តីណែនាំរបស់ក្រសួងការងារ លេខ ០៥៧ និង ០៥៨ ក៏បានកំណត់ដែរថា និយោជកមានសិទ្ធិក្នុងការដកយកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំនួន ៥ភាគរយ មកវិញដែរ។
- យោងតាមកំណត់ហេតុប្រជុំចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ក៏បានកំណត់ដែរថា និយោជកនឹងទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារចំនួន ៥ចំណុច តាមច្បាប់ ដល់កម្មករនិយោជិត ប៉ុន្តែ ចំពោះប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំនួន ៥ភាគរយ ដែលកម្មករនិយោជិតធ្លាប់បានកន្លងមក និយោជកនឹងដកយកមកវិញ។
- មុននឹងបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិតម្នាក់ៗ និយោជកបានហៅកម្មករនិយោជិតនោះមកជួប នឹងប្រគល់ក្រដាសទូទាត់ប្រាក់បំណាច់ចំនួន ៥ចំណុចនេះ ដល់កម្មករនិយោជិតមុន ចំនួន ២ថ្ងៃ ដើម្បីឱ្យពួកគាត់មានពេលវេលាក្នុងការពិនិត្យ និងពិភាក្សាគ្នាជាមួយនឹងតំណាងរបស់គាត់មុននឹងទទួលប្រាក់បំណាច់ទាំងនេះ។ ក្នុងករណីនេះដែរ កម្មករនិយោជិតក៏យល់ព្រមទទួល ហើយមានកិច្ចព្រមព្រៀងរបស់កម្មករនិយោជិតម្នាក់ៗ ក្នុងការទទួលយកការទូទាត់ប្រាក់បំណាច់នេះ និងព្រមព្រៀងឱ្យនិយោជកដកយកប្រាក់ ៥ភាគរយនេះ ដែរ។
- មានលិខិតយល់ព្រមលើការទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារពីកម្មករនិយោជិតម្នាក់ៗ។

- ភាគីកម្មករនិយោជិតឆ្លើយតបនឹងការលើកឡើងរបស់និយោជកខាងលើថា ៖
  - ករណីនេះ ក៏មានសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលសម្រេចថា ឱ្យនិយោជកទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារតាមកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ចំនួន ៥ចំណុច ហើយនិយោជកមិនអាចដកយកប្រាក់បំណាច់ចំនួន ៥ភាគរយ ដែលឱ្យកន្លងមកវិញបានទេ ក្នុងនោះមានសំណុំរឿងក្រុមហ៊ុន ខេមបូ យុងស៊ីង និងសំណុំរឿងក្រុមហ៊ុន ពូយៀន ជាដើម (ប៉ុន្តែ កម្មករនិយោជិតមិនចាំលេខសេចក្តីបង្គាប់)។
  - នៅក្នុងកំណត់ហេតុប្រជុំ គឺមានកំណត់អំពីការដកយកប្រាក់ ៥ភាគរយនេះ មែន ប៉ុន្តែកំណត់ហេតុប្រជុំនេះ មិនអាចយកមកអនុវត្តបានទេ រីឯការព្រមព្រៀងរបស់កម្មករនិយោជិត ក៏មិនអាចអនុវត្តបានដែរ ព្រោះវាផ្ទុយពីមាត្រា ១៣ នៃច្បាប់ស្តីពីការងារ។
  - រីឯសេចក្តីណែនាំរបស់ក្រសួងការងារដែលនិយោជកលើកឡើងខាងលើ គឺកម្មករនិយោជិតសុំបដិសេធការអនុវត្ត ព្រោះសេចក្តីណែនាំនេះ គឺធ្វើឱ្យខូចប្រយោជន៍របស់កម្មករនិយោជិត។

## ហេតុផលនៃសេចក្តីសម្រេច ៖

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាអំពីភាគីដើមបណ្តឹង ដូចខាងក្រោម ៖

កថាខណ្ឌទី១ នៃមាត្រា ៥៤ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ចែងថា ៖ *"ភាពជាតំណាងបំផុតនៃសហជីពត្រូវបានទទួលស្គាល់នៅក្នុងក្របខ័ណ្ឌនៃសហគ្រាស ឬគ្រឹះស្ថាន។ សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួម ឬដោះស្រាយវិវាទការងាររួម គឺសហជីពដែលមានភាពជាតំណាងបំផុតទទួលបានសិទ្ធិផ្តាច់មុខ។"*។

យោងតាមខ្លឹមសារនៃកថាខណ្ឌទី១ នៃមាត្រា ៥៤ នៃច្បាប់ស្តីពីសហជីពខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ថា មានតែសហជីពដែលមានភាពជាតំណាងបំផុតប៉ុណ្ណោះ ដែលមានសិទ្ធិផ្តាច់មុខនៅក្នុងការចរចាបង្កើតអនុសញ្ញារួម និងដោះស្រាយវិវាទការងាររួមនៅក្នុងសហគ្រាស ឬគ្រឹះស្ថានរបស់ខ្លួន។ សិទ្ធិផ្តាច់មុខ

ក្នុងការដោះស្រាយវិវាទការងាររួមនេះ សំដៅលើសិទ្ធិក្នុងការនាំយកវិវាទ និងធ្វើជាតំណាងឱ្យកម្មករនិយោជិត នៅគ្រប់នីតិវិធីដោះស្រាយវិវាទការងាររួម ដោយរួមបញ្ចូលទាំងនីតិវិធីដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញា-កណ្តាលផងដែរ។ *(សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ១៨០/១៦-ស៊ីម៉ង់ត៍ កម្ពុជា ចក្រីទីង និងលេខ ១៧១/១៦-ដេវើលីន ខូអិលធីឌី)*

នៅក្នុងសំណុំរឿងនេះ មិនមានអង្គហេតុណាមួយបញ្ជាក់ថា នៅក្នុងក្រុមហ៊ុននេះ មានសហជីពដែលមានភាពតំណាងបំផុតទេ។

ប្រការ ១៦ នៃប្រកាសលេខ ៣០៣ ក.ប/ប្រ.ក.គ.ប.ក ស្តីពីភាពជាតំណាងបំផុតនៃសហជីព និងបែបបទ និងនីតិវិធីដើម្បីទទួលបានភាពជាតំណាងបំផុត ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨ ចែងថា ៖ *"ក្នុងករណីសហគ្រាស គ្រឹះស្ថានដែលពុំទាន់មានសហជីព ឬពុំទាន់មានសហជីពដែលមានភាពជាតំណាងបំផុត ការដោះស្រាយវិវាទការងាររួម ត្រូវដោះស្រាយដោយអ្នកតំណាងកម្មករនិយោជិត។"*។

លើសពីនេះ ប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ស្តីពីការធ្វើប្រតិភូកម្មមុខងារក្នុងការធ្វើបណ្តឹងអំពីវិវាទការងាររួម និងចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចែងថា ៖ *"ត្រូវបានធ្វើប្រតិភូកម្មជូនដល់ប្រធាននាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត នូវមុខងារ ដូចខាងក្រោម ៖*

...

*- ចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា សម្រាប់ដោះស្រាយវិវាទការងាររួម។"*។

យោងតាមប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ថា នាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មានមុខងារក្នុងការទទួលស្គាល់កម្មករនិយោជិត ឱ្យធ្វើជាតំណាងរបស់ភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម។ ដូច្នេះ កម្មករនិយោជិតដែលត្រូវបានទទួលស្គាល់ដោយនាយកដ្ឋានវិវាទការងារ ឬប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មានសិទ្ធិស្របច្បាប់ក្នុងការតំណាងឱ្យភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម ដោយរួមទាំងនៅដំណាក់កាលដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ នៅពេលមិនទាន់មានវត្តមានរបស់សហជីពមានភាពតំណាងបំផុត។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ២២៣/១៦-យូនីកតាវេកណេឡជី (ខេមបូឌា), លេខ ២២៤/១៦-កាស៊ីណូកោះមាស និង សណ្ឋាគារ, លេខ ០០៨/១៧-ថបវើលដ៍ហ្គាមិន (ខេមបូឌា) អិលធីឌី និងលេខ ២៣៧/១៦-ហ្សិណា-ដាយជុង (ខេមបូឌា) អេឡិចត្រូនិច)*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទៅនឹងការបកស្រាយរបស់ក្រុមប្រឹក្សា-អាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

ក្នុងសំណុំរឿងនេះ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិត ក្នុងការដោះស្រាយវិវាទការងាររួម លេខ ០០៣ ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៩ ដែលមានកម្មករនិយោជិត ចំនួន ៣នាក់ មានឈ្មោះ ១.ម៉ៃ សាមិត្ត , ២. ឆែម វណ្ណៈ និង ៣.ប៊ុត មួយ ជាអ្នកតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន វ៉ាយធីស៊ីខ្មែរប្រ៊ូវើរី ក្នុងការដោះស្រាយវិវាទការងាររួម។ នៅថ្ងៃសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺមានវត្តមានរបស់កម្មករនិយោជិតដែលជាអ្នកតំណាងភាគីកម្មករនិយោជិត ចំនួន ៣នាក់ ខាងលើ។

THE ARBITRATION COUNCIL

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតចំនួន ៣នាក់ ខាងលើ គឺមានសិទ្ធិធ្វើជាតំណាងកម្មករនិយោជិត នៃក្រុមហ៊ុន វ៉ាយធីស៊ី ឧបប៉ូរេសិន ក្នុងការដោះស្រាយវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្របតាមប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាចំណុចវិវាទនៅក្នុងសំណុំរឿងនេះ សម្រាប់កម្មករនិយោជិតនៃក្រុមហ៊ុន វ៉ាយធីស៊ី ឧបប៉ូរេសិន ដែលជាដើមបណ្តឹង។

**ចំណុចវិវាទទី១ និងទី២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកសងប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំនួន ៥ភាគរយ ជូនកម្មករនិយោជិតចំនួន ៧៣នាក់ វិញ ទោះបីជានិយោជកបានទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារចំនួន ៥ ចំណុច តាមច្បាប់ហើយក៏ដោយ**

យោងតាមអង្គហេតុ នៅពេលបញ្ចប់កិច្ចសន្យាការងារកម្មករនិយោជិតទាំង ៧៣នាក់ គឺនិយោជកបានទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារចំនួន ៥ចំណុច មានដូចជា៖ ប្រាក់បំណាច់បណ្តេញចេញ, ប្រាក់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់, ប្រាក់បំណាច់ទូទាត់ជួសការជូនដំណឹងមុន, ប្រាក់សោហ៊ុយជំងឺចិត្ត និងប្រាក់ឈ្នួលចុងក្រោយ ជូនពួកគាត់តាមប្រភេទកិច្ចសន្យាការងារមានថិរវេលាមិនកំណត់។ ប៉ុន្តែ និយោជកបានដកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំនួន ៥ភាគរយ ដែលកម្មករនិយោជិតធ្លាប់ទទួលបានកន្លងមក នៅពេលចប់កិច្ចសន្យាការងារដែលមានកំណត់ថិរវេលាម្តងៗនោះមកវិញ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា តើនិយោជកមានសិទ្ធិដកយកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំនួន ៥ ភាគរយ ដែលនិយោជកធ្លាប់ផ្តល់ឱ្យកម្មករនិយោជិតមកវិញ ករណីនិយោជកបានទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារចំនួន ៥ចំណុច ត្រឹមត្រូវតាមច្បាប់ជូនកម្មករនិយោជិតរួចហើយ ដែរ ឬទេ ?

កថាខណ្ឌទី៦ មាត្រា ៧៣ នៃច្បាប់ស្តីពីការងារ បានចែងថា ៖ "*នៅពេលបញ្ចប់កិច្ចសន្យា និយោជកត្រូវផ្តល់ឱ្យកម្មករនិយោជិតនូវប្រាក់បំណាច់បញ្ចប់កិច្ចសន្យានោះដែលសមាមាត្រនឹងប្រាក់ឈ្នួលផង សមាមាត្រនឹងថិរវេលានៃកិច្ចសន្យាការងារផង ហើយដែលចំនួនប្រាក់បំណាច់នេះមានកំណត់ក្នុងអនុសញ្ញារួម។ បើគ្មានកំណត់ក្នុងអនុសញ្ញារួមទេ ប្រាក់បំណាច់នេះ យ៉ាងតិចត្រូវស្មើប្រាំភាគរយនៃប្រាក់ឈ្នួលដែលកម្មករនិយោជិតបានបើកនៅក្នុងរយៈពេលនៃកិច្ចសន្យា*"។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ បកស្រាយថា កាតព្វកិច្ចនៃការបង់ប្រាក់បំណាច់កិច្ចសន្យាការងារដែលមានកំណត់ថិរវេលាដែលនិយោជកត្រូវបង់ គឺនៅពេលដែលកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាត្រូវបានបញ្ចប់ ហើយទំនាក់ទំនងរវាងភាគីនិយោជក និងកម្មករនិយោជិតត្រូវបានកាត់ផ្តាច់។ *(សេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ៦០/០៦-ញូមេក ហ្គាមេន ហេតុផលនៃចំណុចវិវាទទី៦, លេខ ៩៩/០៦-សៅជ៍ បាយ ហេតុផលនៃចំណុចវិវាទទី៦, លេខ ៨៥/០៩- ណាន់ គ័ង ហេតុផលនៃចំណុចវិវាទទី៤, និងលេខ ១២៤/០៩-ហ្វូកឹស ហ្វូតវៀ ហេតុផលនៃចំណុចវិវាទទី៣)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលកត់សំគាល់ឃើញថា កាលណាកិច្ចសន្យាការងារដែលមានកំណត់ថិរវេលារបស់កម្មករនិយោជិត ប្តូរទៅជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ តាមច្បាប់ស្តីពីការងារនិយោជកមិនមានកាតព្វកិច្ចបង់ប្រាក់បំណាច់កិច្ចសន្យាការងារ ដែលមានកំណត់ថិរវេលា ៥ ភាគរយ ទេ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានសិទ្ធិទាមទារឱ្យកម្មករនិយោជិតសងត្រឡប់មកវិញ នូវប្រាក់បញ្ចប់កិច្ចសន្យាការងារ ចំនួន ៥ ភាគរយ ដែលនិយោជកផ្តល់ទូទាត់ជូនកម្មករនិយោជិតកន្លងមក ដោយគិតចាប់ពីពេលដែលនិយោជកចាប់ផ្តើមផ្តល់ប្រាក់ចំនួន ៥ ភាគរយនេះ រហូតដល់ថ្ងៃដែលនិយោជកបញ្ចប់កិច្ច

សន្យាជាមួយកម្មករនិយោជិត។ *(សេចក្ដីសម្រេចអាជ្ញាកណ្ដាលសំណុំរឿងលេខ ៩០/១០-សៅជ៍ បាយ ហេតុផលនៃចំណុចវិវាទទី១, និងលេខ ៣៣០/១៥-គីន តាយ ហ្គាមិន ហេតុផលនៃចំណុចវិវាទទី២)* .

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅក្នុងសំណុំរឿងមុនៗដែរ។

ក្នុងសំណុំរឿងនេះ ភាគីទាំងពីរទទួលស្គាល់ថា នៅពេលផ្ដាច់កិច្ចសន្យាការងារនិយោជកបានទូទាត់ប្រាក់បំណាច់ផ្ដាច់កិច្ចសន្យាការងារ តាមប្រភេទកិច្ចសន្យាការងារដែលមានថិរវេលាមិនកំណត់ដែលមានចំនួន ៥ចំណុច តាមច្បាប់ ជូនកម្មករនិយោជិតរួចរាល់ហើយ ដោយគាត់យកប្រាក់ ៥% ដែលបានបើកជូនកម្មករនិយោជិតកន្លងមក។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា និយោជកមិនមានកាតព្វកិច្ចក្នុងការផ្ដល់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា ៥ភាគរយ ដល់កម្មករនិយោជិតដែលមានកិច្ចសន្យាការងារមានថិរវេលាមិនកំណត់នោះទេ ហេតុនេះ និយោជកមានសិទ្ធិក្នុងការដកយកប្រាក់បំណាច់បញ្ចប់កិច្ចសន្យា ៥ភាគរយ មកវិញ នៅពេលដែលនិយោជកបញ្ចប់កិច្ចសន្យាការងារជាមួយកម្មករនិយោជិតក្រោមកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ដែលមានន័យថា កិច្ចសន្យាការងារ ឬទំនាក់ទំនងការងារត្រូវបានកាត់ផ្ដាច់។

ជាងនេះទៀត សេចក្ដីណែនាំ លេខ ០៥៧/១៩ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ ស្ដីពីការបើកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ សម្រាប់សហគ្រាស គ្រឹះស្ថានផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង ត្រង់ផ្នែក ទីIV ការផ្ដល់ប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារតាមប្រភេទនៃកិច្ចសន្យាការងារ បានកំណត់ថា ៖

*"១. បើកិច្ចសន្យាការងារមានកំណត់ថិរវេលាត្រូវបានប្រើប្រាស់លើសថិរវេលាដែលកំណត់ដោយច្បាប់គិតរហូតមកដល់ឆ្នាំ២០១៨ ការបើកប្រាក់បំណាច់អតីតភាពការងារត្រូវកំណត់ ដូចខាងក្រោម ៖*

- *ក្នុងករណីកម្មករនិយោជិតបានទទួលប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ(៥%) តាមកាលកំណត់ម្ដងៗរួចហើយ កម្មករនិយោជិតមិនអាចទទួលបានប្រាក់បំណាច់អតីតភាពការងារ ទៀតទេ។...។*

*២. បើកិច្ចសន្យាការងារមានកំណត់ថិរវេលា (FDC) ត្រូវបានប្រែក្លាយជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC) ក្នុងឆ្នាំណាមួយ គិតរហូតមកដល់ឆ្នាំ២០១៨ ការបើករំលឹកប្រាក់បំណាច់អតីតភាពការងារត្រូវកំណត់ ដូចខាងក្រោម ៖*

- *ក្នុងករណីកម្មករនិយោជិតបានទទួលប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ (៥%) តាមកាលកំណត់ម្ដងៗ ក្នុងអំឡុងពេលប្រើប្រាស់កិច្ចសន្យាមានកំណត់ថិរវេលារួចហើយ និយោជកមានកាតព្វកិច្ច បើកផ្ដល់តែប្រាក់រំលឹកអតីតភាពការងារ ដែលមិនទាន់បានបើករហូតដល់ដាច់ឆ្នាំ២០១៨ ប៉ុណ្ណោះ ពោលគឺ មិនតម្រូវឱ្យទូទាត់ពីពេលផ្ដើមដំបូងនៃកិច្ចសន្យាការងារដែលមានកំណត់ថិរវេលានោះឡើយ។...។*

មាត្រា ៤៧ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ បានចែងថា៖ *"រដ្ឋមន្ត្រីមានសិទ្ធិចេញប្រកាស សេចក្ដីសម្រេច សារាចរ និងសេចក្ដីណែនាំ។*

THE ARBITRATION COUNCIL

*ប្រកាស សេចក្តីសម្រេច សារាចរ ឬសេចក្តីណែនាំរបស់ក្រសួង មិនអាចចែងអំពីកិច្ចការដែលមិនស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងនោះ ហើយក៏ពុំអាចមានទំនាស់ជាមួយលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាលឡើយ។"*

យោងតាមមាត្រា ៤៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា រដ្ឋមន្ត្រីមានសិទ្ធិក្នុងចេញប្រកាស សេចក្តីសម្រេច សារាចរ និងសេចក្តីណែនាំផ្សេងៗ អំពីកិច្ចការដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រសួងនោះ ប៉ុន្តែរាល់ការចេញប្រកាស សារាចរ សេចក្តីសម្រេច ឬសេចក្តីណែនាំនោះ មិនត្រូវផ្ទុយនឹងលិខិតបទដ្ឋានគតិយុត្តនានានោះទេ។ ហេតុនេះ យោងតាមការណែនាំលេខ ០៥៧/១៩ របស់ក្រសួងការងារខាងលើ គឺភាគីនិយោជក និងកម្មករនិយោជិតមានកាតព្វកិច្ចក្នុងការអនុវត្តតាមការណែនាំនេះ។ ប៉ុន្តែ ប្រសិនបើភាគីណាមួយ ឬភាគីទាំងពីរ យល់ឃើញថា ការណែនាំនេះផ្ទុយពីច្បាប់ ហើយបានធ្វើឱ្យពួកគាត់ខូចខាតប្រយោជន៍ ឬប៉ះពាល់ដល់សិទ្ធិរបស់គាត់ នោះពួកគាត់មានសិទ្ធិក្នុងការប្តឹងជំទាស់ទៅក្រសួងសាមី ឬស្ថាប័នមានសមត្ថកិច្ចដើម្បីបកស្រាយទៅលើច្បាប់ និងសេចក្តីណែនាំនេះ។ ជាងនេះទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនមានសមត្ថកិច្ចក្នុងការពិនិត្យ និងបកស្រាយថា ច្បាប់ និងសេចក្តីណែនាំខាងលើ មានភាពផ្ទុយគ្នាឬយ៉ាងណានោះទេ។

សរុបមក យោងតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងសេចក្តីណែនាំលេខ ០៥៧/១៩ ខាងលើ គឺនិយោជកមានសិទ្ធិក្នុងការដកយកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំនួន ៥ភាគរយ ពីកម្មករនិយោជិតមកវិញ នៅពេលដែលនិយោជកបានទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារដែលមានថិរវេលាមិនកំណត់ ចំនួន ៥ចំណុច ត្រឹមត្រូវតាមច្បាប់ ជូនកម្មករនិយោជិត។ ហេតុនេះ ការទាមទាររបស់កម្មករនិយោជិតឱ្យនិយោជកសងប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំនួន ៥ភាគរយ ជូនកម្មករនិយោជិតវិញ នៅពេលនិយោជកបានទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារមានថិរវេលាមិនកំណត់ត្រឹមត្រូវតាមច្បាប់ស្តីពីការងាររួចហើយ គឺជាការទាមទារដែលមិនមានមូលដ្ឋានច្បាប់ណាគាំទ្រនោះទេ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកសងប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំនួន ៥ភាគរយ ជូនកម្មករនិយោជិតចំនួន ៧៣នាក់វិញ ទោះបីជានិយោជកបានទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារចំនួន ៥ ចំណុច តាមច្បាប់ស្តីពីការងារ ហើយក៏ដោយ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១ និងទី២ ៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកសងប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំនួន ៥ ភាគរយ ជូនកម្មករនិយោជិតចំនួន ៧៣ នាក់ វិញ ទោះបីជានិយោជកបានទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារចំនួន ៥ ចំណុច តាមច្បាប់ស្តីពីការងារ ហើយក៏ដោយ។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិន មានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាម រយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ។*

THE ARBITRATION COUNCIL

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា ៖ --------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **លីវ សុវណ្ណា**

ហត្ថលេខា ៖--------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ --------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL